# <u>ពិធីស្រង់ទឹកមាតាបិតា</u>

ពិធីនេះកូនចៅបានធ្វើជាហូរហែមកហើយតាំងពីថ្ងៃចូលប៉ុន្តែនៅថ្ងៃទី៣ដែលជាថ្ងៃឡើងស័កនេះមានសភាពប្លែកជាងថ្ងៃមុនៗ ។ នៅថ្ងៃនេះគឺគេបានរៀបចំអាសនៈមួយឱ្យផុត ពីដីហើយរែកទឹកយកមកអប់ដោយគ្រឿងអប់ផ្សេងៗ យកទៅតំកល់ទុកនៅទីនោះឱ្យហើយជា ស្រេច ។ ហើយកូនចៅ ប្រុស-ស្រីអញ្ជើញមាតាបិតា ចាស់ព្រឹទ្ធាចារ្យ ឱ្យអង្គុយនៅទីនោះ ។ បន្ទាប់មកគេក៏និមន្តព្រះសង្ឃសូត្រ នូវព្រះបរិត្ត មាន **រតនសូត្រ** ជាដើមជាពរជ័យសិរីសួស្តី ដល់ មាតាបិតា ចាស់ព្រឹទ្ធាចារ្យរបស់គេទាំងអស់គ្នា ។ រួចមកគេទាំងអស់គ្នា បានធ្វើពិធីសុំខមា ទោសអំពីមាតាបិតា និងចាស់ព្រឹទ្ធាចារ្យ ដោយសុំឱ្យមាតាបិតា និងចាស់ព្រឹទ្ធាចារ្យ មេត្តាខន្តីអភ័យទោស លើកលែងទោសឱ្យកូនចៅ នូវកំហុសទាំងឡាយដែលកូនចៅប្រុស-ស្រីបានធ្វើមួយឆ្នាំកន្លងមកនេះ ទោះដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី សូមមាតាបិតានិងចាស់ព្រឹទ្ធាចារ្យអនុគ្រោះដល់កូនចៅប្រុស-ស្រីផង ។ លុះចប់កិច្ចខមាទោសហើយ កូនចៅប្រុស-ស្រីយកផ្តិលដងទឹកស្រោចទៅលើរាងកាយ មាតាបិតា និងចាស់ព្រឹទ្ធាចារ្យថ្នមៗ ហើយយកដៃដុសជម្រះមន្ទិល ។ បន្ទាប់មកទៀត កូនចៅត្រូវយកសំពត់ ខោអាវ ក្រមាថ្មីៗ ព្រមទាំងបច្ច័យលើកជូនមាតាបិតា និងចាស់ព្រឹទ្ធាចារ្យ អំពើនេះចាត់ទុកថា ជាកិច្ចតបគុណមួយយ៉ាងសមរម្យបំផុតរបស់កូនចៅប្រុស-ស្រីចំពោះមាតាបិតា និងចាស់ព្រឹទ្ធាចារ្យ ។